# ការសម្ភាសន៍ឈ្មោះ បងប្រុស ឌឿង

កៈ អ្នកសម្ភាសឈ្មោះ រត្ន ស្រីភាព ខៈ អ្នកទទួលសម្ភាសឈ្មោះ បងប្រុស ឌឿង

កៈ ចឹងសំរាប់ខ្ញុំសូមណែនាំខ្លួនខ្ញុំសិនចឹងណាបងខ្ញុំឈ្មោះ រត្ន ស្រីភាពធ្វើការអោយកម្រេងជីវប្រវត្តិខ្មែរគឺធ្វើឡើងដោយសកលវិទ្យាល័យមួយដែរមានឈ្មោះថាព្រីយ ហ្គីម យីងដែរនៅអាមេរិចចឹងណាបង?

ខៈ អ៊ើរ! មិននៅខ្មែរយើងចឹង។

កៈ ចាំ! មិនមែនទេប៉ុន្តែពួកយើងធ្វើការសម្ភាសនេះគឺយើងថែរក្សាទុកអោយកូនខ្មែរជំនាន់ក្រោយឬមួយទុកអោយប្រជាជនផ្សេងៗទៀតដូចជាបទេសដែរគាត់ចូលចិត្តស្តាប់ប្រវត្តិរូបខ្មែរយើងណា?

ខៈ បាទ!

កៈ អោយបានដឹងថាក្នុងការរស់នៅរបស់ពួកយើងមានការពិបាកទុកការតស៊ូរមានការអើយឆ្លងកាត់ឧបសគ្គជាច្រើននៅក្នុងជីវិតទំម្រេងតែបានស្រណុកនឹងគឺមិនងាយចឹងណាបង?

ខៈ បាទ!

កៈ ចាំ! ចឹងសំរាប់ខ្ញុំចឹងសំរាប់ខ្ញុំធ្វើការសម្ភាសនេះគឺធ្វើឡើងនៅថ្ងៃទី០២ នៅខែ០២ នៅឆ្នាំ២០២០ណាបងណា ចាំ ចឹងអាជាស្រ័យសំរាប់បងតើបងមានឈ្មោះ អ្វីដែរបង?

ខៈ ខ្ញុំឈ្មោះ ឌឿង ៕

កៈ ចាំ តើនៅក្នុងបញ្ជីគ្រួសារតើបងមាននាមត្រកូលអ្វីដែរ?

ខៈ អ៊ើរ អានឹងនេះទៀត៕

កៈ ចាំ៕

ខៈ ចុះគ្រាន់តែសួរត្រឹមឈ្មោះ អត់បាន៕

កៈ ដោយសារតែពួកយើងយកទៅវ៉ៃឯកសារទុកអោយកូនក្មេងជំនាន់ក្រោយអានចឹងណាយើងត្រូវតែដាក់លាក់ចឹងណាបង?

ខៈ បាទ ខ្ញុំនឹងអត់ទេខ្ញុំប្រាប់បានត្រឹមតែឈ្មោះ ទេ។

កៈ ចាំ ចឹងបងមានអាយុនឹងប៉ុន្មានហើយបង?

ខៈ ខ្ញុំអាយុ២៥ ឆ្នាំ។

កៈ សព្វថ្ងៃនឹងអាយុប៉ុន្មាន?

ខៈ អ៊ូរ ៣៥ឆ្នាំ។

កៈ ៣៥ឆ្នាំ លីតែ២៥ឆ្នាំលីថាម៉ារ២៥ឆ្នាំ ចង់ភ័យ
ចង់បងបានកើតនៅឆ្នាំអីដែរនៅឆ្នាំ១៩៨៧?

ខៈ បាទ! ។

កៈ ហើយបងកើតឆ្នាំខ្មែរ ជូត ឆ្លូវ ខាល ថោះ?

ខៈ ថោះ ។

កៈ ឆ្នាំ ថោះ ទីណាស្រុកកំណើតនៅណាដែរ?

ខៈ នៅខេត្តតាកែវ៕

កៈ អើរ នៅខេត្តតាកែវ ចុះសព្វថ្ងៃនឹងមករស់នៅទីក្រុងភ្នំពេញនឹងមកយូរនៅបង?

ខៈ យូរហើយ។

កៈ មូលហេតុអីបានបងមកអើយធ្លាក់ទីលំនៅពីរស្រុកកំណើតមកមកនៅអើយទីក្រុង

ភ្នំពេញ?

ខៈ ស្រុកកំណើតនៅណោះពឹងគ្រាន់តែយើងមកធ្វើការនៅទីក្រុងភ្នំពេញដើម្បីអើយ ។

គៈ ធ្វើការក្នុងជីវភាពគ្រួសារ។

កៈ អើរ ចឹង
អើយសំរាប់ក្រុមគ្រួសាររបស់បងមានការតាមតឹងឬមួយក៏ធូរធាដែរបងតាំងពីរក្មេង?

ខៈ តាម។

កៈ ក្មេងរហូតមកដល់សព្វថ្ងៃ?

ខៈ អឺរ ឥឡូវមានការជម្នតាៗវាមិនបានសូវតាមតឹងប៉ុន្មានក៏វាអត់សូវជាមានប៉ុន្មានដែរ
វាគ្រាន់ម៉ារមធ្យម។

កៈ ម៉ារ មធ្យមចឹងណ៎?

ខៈ បាទ!

កៈ ចា៎! ពីរក្មេងមិចដែរបងជីវិត?

ខៈ ពីរក្មេងជីវិតរស់នៅដូចស្រួយជាងឥឡូវ។

កៈ ជាមួយ!?

ខៈ តែឥឡូវនឹងវាពិបាកវាគឺមិនឹងវាចូលមកច្រើន បើពីរមុននឹងអត់ទេបាយឆ្ងាញ់ ម្ហូបឆ្ងាញ់
ការនឹងគ្មានគឺមីអីចឹងណាពឹងតែឥឡូវនឹងវាពិបាកៗណាស់បាយក៏ឆ្ងាញ់អីក៏មិនបានឆ្ងាញ់
បន្លែងយើងនឹងឥឡូវប្រើតែគីមីដល់ចឹងវាប៉ះពាល់ចឹងសម័យឥឡូវ។

កៈ វាប៉ះពាល់?

ខៈ
ដល់ឥឡូវនឹងត្រឹមតែអាយុ៣០អីនឹងអាយុ៤០អីយើងមានទុកមេរោគនេះមេរោគនោះអីបាត់

ហើយចុះការពីរមុននឹងអត់មានទេចាស់ពីរមុនអត់ទេអាយុ៤០អីនឹងអត់៦០អីជួនកាលទុំអីបានជុះឥឡូវអត់ទេ តើប្រហែលទឹកនោមបង្អែមឥឡូវ
តែប្រហែលលីសឈាមប្រហែលមានរោគនេះរោគនោះវាពិបាកចឹងវាប៉ះពាល់ច្រើនឥឡូវ។

កៈ នៅស្រុកកំណើតរបស់បងមានបងប្អូននឹងប៉ុន្មាននាក់ដែររស់នៅស្រុកកំណើត?

ខៈ ប្រាំបីរនាក់។

កៈ អ៊ើរ ច្រើនដែរណាបងណេរ?

ខៈ បាទ!

កៈ បងកូនទីប៉ុន្មាន?

ខៈ កូនទីបួន។

កៈ កូនទីបួន បងប្អូនប្រុស ស្រីរបស់បងមានប្រុសប៉ុន្មាន ស្រីប៉ុន្មានដែរ?

ខៈ ប្រុសបួន ស្រីបួន។

កៈ ចឹងមានន័យថាចាប់ពីរបងទីបួន ចឹងបងជាកូនច្បងគេ?

ខៈ បាទ!

កៈ ចំានៅក្នុងបងប្អូនទាំងអ៊ើរ ប្រុសបួននាក់នឹងសំរាប់បងផ្ទាល់បងបានរស់នៅស្រុកតាកែវ

តើគេចូលចិត្តធ្វើខ្លះដែរនៅពីរក្មេងរហូតដល់បច្ចុប្បន្ន?

ខៈ ធ្វើស្រែ ធ្វើចំការជាពិសេសធ្វើស្រែតែម៉ងនៅស្រុកតាកែវ ចូលចិត្តធ្វើស្រែ។

កៈ ចុះជោកជ័យច្រើនការធ្វើស្រែនឹង?

ខៈ ជោកជ័យៗ វាចេះតែបានហើយតែវាគ្រាន់តែថាបេលយើងនេះមកវាលក់អត់សូវបាន

ថ្លៃ ចឹងវាធម្មតាយើងធ្វើស្រែវាបានជោកជ័យហើយគ្រាន់ថាពេលគេប្រមូលផលបានទៅ

វាលក់អត់សូវបានថ្លៃហើយចឹងវានៅតែខ្លះខាត់ដ័ដែរ។

កៈ ចុះ
ធ្លាប់ដែរបានចាំថាមានអនុស្សាវរីយណាតាំងពីរក្មេងមករហូតមកដល់សព្វថ្ងៃនេះរស់នៅជាមួយក្រុមគ្រួសារ ធ្វើស្រែបរាជ័យខ្វះខាត់ខ្លាំងបំផុត?

ខៈ អត់ទេ។

កៈ អត់ដែរបានធ្លាប់មានតែបើបានមក?

ខៈ សម័យមុនអត់មាន តែបើសម័យនឹងមាន។

កៈ បរាជ័យច្រើនបងណេរ?

ខៈ នឹងហើយ។

កៈ បរាជ័យនឹងដោយសារអ្វីដែរបងបរាជ័យ?

ខៈ ដោយសារតែ ទីមួយយើង ធម្មតាយើងនឹងធ្វើស្រែ
ជួនកាលយើងនឹងអត់មានលុយខ្លួនឯង យើងទៅចង់ការគេចឹងណា
ដល់ពេលចង់ការគេដល់គេយើងស្រូវនឹង យើងសង់គេអត់បានគ្រប់!
យើងសង់គេអត់បានគ្រប់ចឹងអាស្រូវនឹងដល់ទៅវាប្រើដើមទុងនឹងច្រើន បាចជីបាញ់ថ្នាំ
បូលទឹក បើពីរមុនយើងអត់ ពីរមុនយើងប្រើជី តែជី

តិច ថ្នាំក៏ថ្នាំនឹងតិចដែរ ហើយជីក័វារៀងថោកដែរពីរមុន ត្រឹមតែម៉ារបារពីរ បីម៉ឺនទេពីរមុន

តែដល់ឥឡូវម៉ារបារ ដល់ម៉ឺមជាង តែបើយើងនឹងអត់បានបាច យើងនឹងអត់បានមែន
ចឹងវា

ចេះតែប៉ះពាល់។

កៈ តើបងប្អូនរបស់បង មានសព្វថ្ងៃដែរបានរស់នៅស្រុកកំណើត ប្រាំពីរនាក់នឹងពួកគាត់ត

តែងតែធ្វើស្រែទាំងអស់គ្នា ឬមួយក័ពួកគាត់បានធ្លាក់មុខរបរផ្សេង?

ខៈ មកដល់ឥឡូវនឹងឈប់ធ្វើស្រែអត់ហើយ ធ្វើការ ធ្វើអីផ្សេរអស់ហើយ
រកស៊ីធ្វើសន្តិសុខធ្វើនេះនោះខ្ញុំគេចង់ទៅ រកស៊ីវាមិនបានលុយ។

កៈ លឺថាអ្នកតាកែវបានបងប្អូនជាច្រើនដែរគេចំណត់ស្រុកទៅដល់ប្រទេសថៃ
ហើយបើតាមបងប្អូនរបស់បងធ្លាក់មានទេ?

ខៈ មាន ខ្ញុំនឹងក័បានធ្លាក់។

កៈ រសជាតិមិចដែរចំណត់ស្រុកទៅដល់ប្រទេសថៃនឹង?

ខៈ អើយ យើងទៅនឹងវាមិនដែរបានចេះតែស្រួយ ទៅប្រទេសណាក៏ដូចជាប្រទេសណាដែរ
ប្រទេសណា
តែយើងនេងមិនបានធ្វើដូចម្តេចដើម្បីជីវភាពក្រុមគ្រួសារលេះបង់ហើយនឹងតស៊ូរ។

កៈ សំរាប់បងប្អូនសំសួរបងនៅអ្វីដែរបងបានចង់ចាំ
សំសួរបងរឿងពីរមុនតិចឪពុកម្តាយបងតើគាត់នឹងជាមនុស្សបែនណាដែរ?

ខៈ គាត់មនុស្សល្អគាតនឹងអត់ចេះយកចិត្តទុកដាក់ចំពោះកូន អ្នកចិតខាង
គាត់និយាយអោយចំគាត់នឹងចិត្តល្អ។

កៈ ចំពោះលោកពួក!
ចំពោះបងផ្ទាល់បងអើយរស់នៅជាមួយនឹងបងប្អូននឹងឪពុករបស់បង

ពីរមុនរហូតមកដល់សព្វនឹងគាត់ជាអ្នកធ្វើស្រែ ចំការដើម្បីចិញ្ចឹមបង ទំរេងបានធំធាត់
ណាស់លោកទាំងពីរសព្វថ្ងៃនេះមានវ័យពឹងណាមានអាយុប៉ុន្មាន?

ខៈ គាត់ប្រហែលជា ហុកជាង។

កៈ លោកឪពុកឬមួយក៏អ្នកម្តាយហុកជាង?

ខៈ លោកទាំងពីរអាយុស្មារគ្នា។

កៈ ចឹងមានន័យថាគាត់នឹងមានអាយុហុកពីរស្មោរគ្នា?

ខៈ បាទៗ ប្រហាក់ប្រហែគ្នា។

កៈ គាត់មានឆ្នាំជាមួយនឹងគ្នាឬមួយក័មិចដែរបង?

ខៈ គាត់មានឆ្នាំខុសគ្នា តែគ្រាន់ថាលើសខ្វះគ្នាតែម៉ារតិចម៉ាឆ្នាំពីរឆ្នាំចឹងណា។

កៈ អ៊ឺរ ចំា ម្ដាយឪពុកបងគាត់នឹងមានឈ្មោះ អីដែរបង?

ខៈ គាត់នឹងអត់អាចប្រាប់ឈ្មោះ នឹងបានទេ។

កៈ
ចុះសំរាបញបងផ្ទាល់ពេលដែរបងបានរស់នៅជាមួយនឹងឪពុកម្ដាយចុះបងបានស្រឡាញ់ណាខ្លាំងជាងគេ?

ខៈ បងស្រឡាញ់គាត់ទាំងពីរ។

កៈ សំរាប់ខ្ញុំ! ខ្ញុំស្រឡាញ់ម៉ាកខ្ញុំជាងគេ?

ខៈ ពីព្រោះអីខ្ញុំស្រឡាញ់លោកទាំងពីរ ពីព្រោះគាត់ជាអ្នកមានគុណ
មិនអាចថាយើងនឹងស្រឡាញ់អ្នកអត់អ្នកណា បាទ
គឺយើងនឹងស្រឡាញ់គាត់ស្មារគ្នាចំពោះបងនឹង។

កៈ
ពីរក្មេងមកឪពុកម្ដាយជាអ្នកស្រុកតាកែវជាមួយនឹងគ្នាឬមួយក៏គាត់ត្រូវបានជាអ្នកស្រុលឆ្ងាយ?

ខៈ ជាមួយតែគ្នាជាអ្នកស្រុកគ្នាគាត់នៅជិតខាងគ្នានឹងដែរ។

កៈ
គាត់បានធ្លាប់និយាយប្រវត្តិប្ដីប្រពន្ធអោយលោកពូនឹងបានស្ដាប់ថាគាត់នឹងបានជួបគ្នាដោយសារអី?

ខៈ បាទ! បាទ! នឹងហើយគាត់ធ្លាប់ជួបគ្នាជំនាន់គាត់នៅខ្មែរក្រហម
គាត់ថាគាត់នឹងគេជាប់

គាត់អត់បានការអីផងនឹង គេចាប់គូរមកអោយគាត់ចឹងណា។

កៈ ចំា!

ខៈ ជំនាន់នឹង ចាប់គូរ ងត់មានការអត់មានអីនឹងគេទេ
ចុះដូចជំនាន់អ៊ីុគេបានចាប់គូរទេ។

គៈ បាទ!

ខៈ នឹងគេបាច់គូរ  គេអោយយើងយកមួយណាមួយនឹងហើយ។

គៈ នឹង!

ខៈ បាទ! អោយយកមួយណាមួយនឹងអត់មាន អត់មានជំរើសយើងណា មិនមែនដូចឥឡូវ

វានឹងស្រួយដែរតល់តែយើងនឹងចង់បានយកអត់បានទៅទៀតទៅមុនអត់ទេ។

កៈ ចឹងគាត់បានជួបគ្នានៅក្នុងជំនាន់ខ្មែរក្រហមជាអ្នកគូរគង់ អោយគាត់?

ខៈ នឹងហើយ គេគូរគង់ អាប៉ុល ឬក៏ខ្មែរក្រហមអ៊ីកាលនឹង។

កៈ អាប៉ុល នឹងខ្មែរក្រហមតែមួយនឹង។

កៈ គ្រាន់តែថាអាប៉ុលនឹង កាច់ដែរ តែបើខ្មែរក្រហមវាខូរខៅ ! តែបើយើងនឹងហៅខ្មែរក្រហមវារៀងស្លូតតិច?

កៈ ខ្មែរក្រហមស្លូត។

ខៈ បាទ!

កៈ ដូចគេបានហៅយើងថា កម្ពុជា ?

ខៈ ហើយនឹង។

កៈ ហើយនឹងខ្មែរ?

ខៈ នឹងខ្មែរវាអាក្រក់ពេក។

កៈ នឹងខ្មែរវារៀងអាក្រក់តិច បើគេហៅយើងថា អ៊ើរអ្នកឯងកម្ពុជា នឹងរៀងពិរោះស្តាប់ជាង?

ខៈ បាទ!

កៈ បាទ! ដូចយើងហៅគេថាយួនចឹងណា ហើយនឹងពាក្យ វៀរណាតចឹង បាទ ហើយថៃក៏វាហៅនែ៎ កម្ពុជាដែរហៅយើង កម្ពុឆា។

កៈ កម្ពុឆា! នឹងកម្ពុជា ចឹងអើយសំរាប់បងប្រុសផ្ទាល់ បងអើយបានដឹងថាកាលរស់នៅជាមួយនឹងឪពុកម្តាយជីវភាពពិបាកឬមួយក៏ស្រណុតអីនឹងគឺគាត់ជាអ្នករៀបចំខ្សែរជីវិត?

ខៈ នឹងៗ ។

កៈ ហើយសំរាប់បងវិញតើបងបានរៀបការតាំងពីរអាយុប៉ុន្មាន?

ខៈ អាយុ កាលនឹងប្រហែល២៣។

កៈ ជាមូលហេតុអីបានបងរើសយកអាពាហ៏ពិពាហ៏ទាំងបងនៅវ័យក្មេង?

ខៈ កាលនឹងវាអត់មានជំរើសហើយ ចង់បានប្រពន្ធ។

កៈ ចង់ បានប្រពន្ធ។

កៈ កាលនឹងមកពីរបងចូលចិត្តប្រពន្ធបងខ្លាំងឬមួយក៏បានជាប្រពន្ធខ្លាំងជាង?

ខៈ កាលនឹងអត់ ស្រឡាញ់គ្នាទាំងពីរអ្នក គាត់មានអាយុ៣០ជាងដូចតែបងនឹងដែរ។

កៈ គាត់មានឈ្មោះ អីដែរសុំស្គាល់ឈ្មោះ តិចមកបង?

ខៈ គាត់ឈ្មោះ ស្រីយ៉ារ។

ក៖ អ៊ើរ បងស្រីយ៉ា ! ចាំ មានកូននឹងប៉ុន្មាននាក់ដែរ អនុស្សាវរីយ៍?

ខ៖ អ៊ើរ មានកូនបានពីរនាក់ដែរ។

ក៖ បានកូនពីរនាក់ពិបាក់ទេក្នុងការចិញ្ចឹមកូន?

ខ៖ អត់អី កូនរស់នៅជាមួយនឹងយាយ យើងនៅនេះ យើងនឹងអត់បានដឹងដែរ។

ក៖ ចឹងលោកពូអត់មានភាពជិតស្និតក្នុងការមើលកូនដោយដៃយើងនឹងផ្ទាល់ដែរឆ្លាក់ទេ?

ខ៖ យើងធ្លាក់ដែរ ម្ដងកាល ខ្ញុំធ្លាក់តែពីរកាលខ្ញុំវានៅតូចៗ
ដល់ពេលវានឹងធំទៅវាទៅរស់នៅជាមួយនឹងយាយ យើងមករស់នៅជាមួយនឹងយើង!
យើងអត់បានអោយបានរៀនសូត្រចឹងណា បើយើងនឹងធ្វើការម៉ោរយប់
មួយថ្ងៃយើងធ្វើ១២ម៉ោង យប់ល្ងាចចូលផ្ទះព្រឹលឡើងចេញ បាទ!
បើយើងនឹងអត់បានធ្វើយើងនឹងអត់មានអីស៊ីមានអីចាយ។

គ៖ គ្មានអីស៊ី នឹងចាយ។

ក៖
សំរាប់បងផ្ទាល់តើបងអាចប្រាប់ខ្ញុំបានទេនៅពេលដែរបងចាប់ផ្ដើមអើតរស់នៅជាលមួយនឹងប្ដីប្រពន្ធរបស់បងណាកាលដែរបងបានចាប់ផ្ដើមរៀបការកាលនឹងនៅក្នុងឆ្នាំណាដែរបង!
បងចាប់ទេ?

ខ៖ កាលនឹងដូចជាពីរពាន់ជាង តែខ្ញុំមិនបានដឹងឆ្នាំពីរពាន់ប៉ុន្មាន។

ក៖ ចាំ! បានជូនជំនួញគេប៉ុន្មានថ្លៃម្ចាស់ផ្ទះ?

ខ៖ កាលនឹងអោយបានថោកដែរ អស់ប្រហែលបានតែមួយពាន់ជាង មួយពាន់ប្រាំ។

ក៖ ពីរពាន់ជាង ក្នុងឆ្នាំជំនាន់ពីរពាន់ជាងកាលនឹងបានថ្លៃ?

ខ៖ មួយពាន់ប្រាំ។

ក៖ កាលខ្លាំងណា?

ខ៖ កាលនឹងបានច្រើនកាលនឹង។

ក៖ ចាំ! តើបងកាលនឹងជូនអោយទៅគាត់អោយអស់មួយប្រាំរយនឹង
អើយយើងរស់នៅជាមួយនឹងគ្នាការជាមួយនឹងគ្នាបានកូនពីរតើអាជីវកម្មចិញ្ចឹមកូនសព្វថ្ងៃនឹងប្រើអីខ្លះជាមួយប្រពន្ធទំម្រេងតែបានចិញ្ចឹមកូនបានធំធាត់ដល់ថ្នាក់?

ខ៖ ប្រើអីខ្លះអត់បានយល់។

ក៖ ប្រើការងា អីខ្លះ ឬមួយឆ្លងកាត់?

ខ៖ យើងនឹងប្រកបអាជីវកម្មការងាអីចឹង។

ក៖ ចាំ!

ខ៖ រាល់ថ្ងៃនឹងបងធ្វើកាងារជាសន្តិសុខទៅ ប្រពន្ធខ្ញុំគាត់ធ្វើការនៅហាង
អីទៅបានប្រាក់មកយើងនឹងអោយទៅផ្ទះជួលធ្វើអីខ្លះទៅដល់យើងនឹងបានសល់តិចទួច

យើងនឹងទំលាក់ផ្ទើរអោយកូនអីចឹងណាសំរាប់ផ្គប់ផ្គងដក់គ្រួសារដើម្បីអោយកូននឹងបានរៀនសូត្រ។

កៈ
សំរាប់បងផ្ទាល់តើបងអាចប្រាប់ខ្ញុំបានទេថានៅពេលដែរចិញ្ចឹមកូនពីរនឹងស្រីមួយឬក៏ប្រុសមួយឬមួយក៏ជាស្រីទាំងពីរ?

ខៈ ស្រីមួយអ៊ំរ ប្រុសទាំងពីរ។

កៈ ប្រុសទាំងពីរពិបាកចិញ្ចឹមទេបង?

ខៈ វាអត់ពិបាកទេសំខាន់គឺយើងនឹងអត់មានលុយ កូនវាអត់សូវពិបាកចិញ្ចឹម តែគ្រាន់ថាយើងនឹងអត់មានលុយ។

កៈ ប្រើជីវិតចិញ្ចឹមកូនប្រុសពីរនាក់នឹងគឺមិនអាច មិនទាន់ដឹងថាមានការពិបាកអត់មានកាលឆ្លងកាត់ប៉ុន្មានគេដោយសារតែពួកគាត់នឹងនៅតូចៗរាល់ថ្ងៃនឹងបានបញ្ចូលកូនទៅរៀនថ្នាក់អង្លេសថ្នាក់អីខ្លះទេ?

ខៈ អត់ឥឡូវវាបានរៀននៅខេត្តតែគ្រាន់គេខេត្តនឹងមានម៉ោងរៀនគួរអង្គេសអីនឹងដែររៀនគួរអង្គេសរៀនគួរចិនអីចឹង ដើម្បីយើងពីព្រោះសព្វថ្ងៃយើងផ្តោតទៅលើអង្គេសនឹងចិនអីចឹងទៅណា។

កៈ
ចុះសំរាប់បងផ្ទាល់នៅពេលដែរបងអើយនៅពីរក្មេងបងបានរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរបង?

ខៈ ថ្នាក់ទីប្រាំបីរបងជំនាន់នឹង។

កៈ កាលនឹងមានប្រើប្រាក់ជាភាសាបទេសអីចូល?

ខៈ ប្រើតើកាលនឹងប្រើអង្គេសកាលនឹងតែជំនាន់នឹងរៀនដូចអ់បានចូលហើយនឹងអត់ចេះ។

គៈ វាអាលែងតែប្រពន្ធស្រី ប្រពន្ធវានេងពេក។

ខៈ
អត់ទេរៀននឹងអត់ចូលហើយខ្ញុំនឹងអត់ចេះកាលនឹងយើងអត់បានរៀនគួរអីចឹងកាលនេងជីវភាពគ្រួសារយើងនឹងវាអត់មានលុយកាកអីដើម្បីថាមានម៉ោងរៀនគួរអត់សូវមានពេល

បើជំនាន់នឹងយើងមកពីរៀនវិញយើងនឹងទៅស្រែអីច្រូវស្មៅគោអីចឹងទៅធ្វើស្រែធ្វើនេះ

ធ្វើនោះណា
វាអត់បានដូចជំនាន់ឥឡូវបើគោនឹងលក់អស់ហើយនឹងមានអីនឹងមើលទៀតដល់ម៉ោងនឹងតែរៀនហើយនឹងសូត្រវាពិបាកជំនាន់មុនសំរាប់ការរៀនសូត្រ។

កៈ នៅពេលដែរបងអើយរស់នៅជាមួយនឹងប្រពន្ធបងបានជួបគ្នាដំបូងនៅកន្លែងណាដែរ

កន្លែងធ្វើការឬមួយក៏អ្នកភូមិជិតគ្នា?

ខៈ នៅកន្លែងធ្វើការនៅភ្នំពេញ ។

កៈ ជួបគ្នានៅកន្លែងធ្វើការណាបងនែ៎?

ខ៖ នឹងហើយ!

ក៖ ចាំ! បងអើយបងឯងបានរៀននៅសាលាថ្នាក់ទីប្រាំបីរ
ហើយនឹងទីប្រាំបួននៅសាលានៅខេត្តមានឈ្មោះ អីគេដែរបង?

ខ៖ សាលានៅខេត្តតាកែវ។

ក៖ គេបានដាក់សាលានៅខេត្តតាកែវ?

ខ៖ បាទ!

ក៖ កាលនឹងគេបានដាក់សាលាអនុវិទ្យាល័យនៅ?

ខ៖ ចូលហើយអូន! ចួលហើយ។

ក៖ ចួលហើយណំ!?

ខ៖ អនុវិទ្យាល័យ។

ក៖ ចាំ! ហើយកាលនឹងមានមិត្តភ័ក្រ្តជិតស្និតជាមួយនឹងគ្នាទេ?

ខ៖ មាន! មាន!  មិត្តភ័ក្រ្ត។

ក៖
ចំពោះបងផ្ទាល់តើបងអាចប្រាប់បានទេនៅពេលដែរបងបានរស់នៅជាមួយនឹងអើយជីវិត
កាលនៅរៀននឹងមានមិត្តភ័ក្រ្តណាជិតស្និតជាមួយនឹងគ្នាហើយមានអនុស្សាវរីយផ្លាក់ឆ្លង
កាត់ជាមួយនឹងគ្នាមានខ្លះទេ?

ខ៖ មាន! មាន! ពឹងតែជំនាន់នឹងពេលដែរយើងនឹងចេញពីររៀនអីនឹង
ដល់ពេលចឹងទៅយើងនឹងទៅច្រូវស្មៅគោស្មៅអីជាមួយនឹងគ្នាចឹងទៅណា
ជំនាន់នឹងតែឥឡូវនឹងវាបានមានគ្រួសារអស់ ! អស់ហើយបានគ្រួសារនៅតាមខេត្តផ្សេង!
ផ្សេងពីគ្នាមកដល់ឥឡូវនឹងនោះ។

ក៖ បងអើយអាចប្រាប់បានទេថាពីរសង្គមមកបងរស់នៅជាមួយនៅជាមួយឪពុកម្តាយ
ជាមួយនឹងលោកតាលោកយាយ
ពួកគាត់នឹងមិចដែរហើយគាត់មានបានរស់នៅទាំងសង់ខាងឬមួយ
ក៏បានបាត់បង់ជំនាន់ខ្មែរក្រហមអីខ្លះ?

ខ៖ អត់ទេ! ឥឡូវគាត់រស់នៅទាំងងស់ខាង គាត់ទើបបានបាត់បង់ឥឡូវនឹងដែរ។

ក៖ ចឹងអត់មានបងប្អូនណាឬមួយ ក៏លោកយាយលោកតា
ណាដែរបានបាត់បង់ជីវិតជំនាន់ខ្មែរក្រហមទេនំ?

ខ៖ មាន! មាន!
បងៗលឺថាបងខាងម៉ែខ្ញុំបង្កើតបានបាត់បង់ជំនាន់ខ្មែរក្រហមនឹងម្នាក់ដែរបានបាត់បង់
ទៅយើងនឹងមិនបានដឹងរស់នៅឬមួយក័គាត់នឹងបានស្លាប់ទេពីព្រោះតែសម័យឥឡូវនឹងក៏
មិនបានទាន់ដឹងដំណឹងស្លាប់ឬមួយក៏គាត់នឹងរស់ដែរ សម័យឥឡូវនឹងមានឈ្មោះ
ថាយាយមុត?។

ក៖ ដល់ពេលបងអើយគិតថាពេលខ្លះគិតថាគាត់នឹងស្លាប់ៗ
ស្រាប់តែគាត់ទៅនៅប្រទេសអីនឹង ធ្លាក់ស្រម៉ៃគិតខ្លះទេ?

ខ៖ នឹងហើយខ្ញុំធ្លាក់មានបងប្អូន ធ្លាក់ស្រម៉ៃគិតចឹងដែរតែគ្រាន់ថា
បើគាត់នឹងរស់នៅប្រទេសគាត់នឹងមកហើយពីព្រោះអីតាំងពីរមើល ហារ ហុក
សិបឆ្នាំហើយតែបើគាត់បានរស់នៅដល់ឥឡូវក៏គាត់មកផ្ទះ បើគាត់នឹងនៅរស់គាត់នឹងមក
មិនដែរថាគាត់មិនស្គាល់ថាបងប្អូនបានរស់នៅស្រុកនេះ
ទោះបីមិចក៍យើងនឹងត្រូវមកអើកបងប្អូនថា អ៊ឺរ ឥឡូវបងប្អូន

នៅរស់ឬមួយគាត់នឹងបានស្លាប់អីចឹងទៅណា បើគាត់ស្លាប់គាត់នឹងមិន
ហើយយាយតាអីក៍គាត់បានស្លាប់ដែរ គាត់ស្លាប់ប្រហែលយាយជាងបីរបួនប្រាំនឹង
តាគាត់ទើបនឹងបានស្លាប់ឆ្នាំទៅនឹង។

ក៖ យាយតាខាងឪពុកម្ដាយបង?

ខ៖ នឹងហើយ! នឹងហើយ។

ក៖ ទាំងសង់ខាង ?

ខ៖ ខាងម្ដាយ! ខាងឪពុកគាត់បានស្លាប់អស់។

ក៖ ស្លាប់ពីរជំនាន់ណាមកដែរបង?

ខ៖ ទើបនឹងបានស្លាប់ឥឡូវៗដែរនឹង។

ក៖ អ៊ឺរៗ មិនមែន គាត់ៗតស៊ូរពីររបបខ្មែរក្រហមបានផុត?

ខ៖ នឹងហើយ! នឹងហើយ! គាត់ធ្លាប់និយាយប្រាប់ចឹងណា ម៉ារជំនាន់មុនពិបាកអីចឹងទៅ។

ក៖ ចាំ! គាត់នឹងបានតស៊ូរបានច្រើនណាបង?

ខ៖ បាទ! ។

ក៖
បងអើយបងរស់នៅជាមួយនឹងជិវិតរបស់បងតើអើយបងមានធ្លាក់ដើរស៊ីឈ្នួសអីអោយគេ
ទេកាលពីរវ័យកុមាររហូតមកដល់សព្វថ្ងៃ?

ខ៖ អ៊ឺរ! ស៊ីឈ្នួស
ខ្ញុំធ្លាក់ស្រូចកាត់អោយគេហើយខ្ញុំដើរស៊ីឈ្នួសបោកបែង(បោកបែងមានន័យថាយកស្រូវចេញពីរដើម) អោយគេអីចឹងណា
ជំនាន់នឹងអត់សូវមានលុយកាកអីចាយទេតែគ្រាន់បើពីរស្រូវវិញហូបគ្រប់គ្រាន់ជំនាន់នឹង។

ក៖ ចាំ!

ខ៖
ស្រូវបាយម្ហូបអីយើងហូបដឹងតែពីឆ្ងាយចឹងជំនាន់នឹងតែគ្រាន់ថាលុយយើងអត់មានអីចាយ
ដឹងតែត្រីដឹងថាម្ហូបបាយអី
ពេលដែរយើងនឹងបានហូបដឹងតែឆ្ងាយតែម៉ងតែគ្រាន់ដាយើងនឹងអត់មានលុយចាយតែ
គ្រាន់ជំនាន់នេះយើងមានលុយតែគ្រាន់តែម្ហូបហូបទៅគឺយើងនឹងអត់បានដឹងរសជាតិបើ
យើងនឹងចង់ដឹងរសជាតិទល់តែយើងនឹងអស់មួយរយ

ពីររយដុល្លារណ៎នឹងបានយើងដឹងរសជាតិតែគ្រាន់ថាយើងនឹងម្ហូបសាញ្ញាមជម្មតាអានឹងយើងអត់មានដឹងរសជាតិចឹងបានថាវាមិនស្រួយ
ត្រីយើងស្អិតតែចឹញ្ចឹមយើងអត់បានដូចពីរមុន។

ក៖ ចុះបងអើយធ្វើការស៊ីឈ្នួសដក់ស្ទូនកាលនឹងគិតជាប្រាប់ខែឬមួយគិតជាថ្ងៃកាលនឹង?

ខ៖ គិតជាថ្ងៃកាលនឹង មួយថ្ងៃបានបីរពាន់ជាង ពីរពាន់ បីរពាន់។

ក៖ មួយថ្ងៃបានពីរ បីរពាន់ទេ?

ខ៖ ពីរ បីរពាន់ បីរពាន់ប្រាំលុយខ្មែរយើងនឹងពីរដើម។

ក៖ អើយ ! ប៉ន្តែបានច្រើនចឹងបងនែ៎?

ខ៖ នឹងហើយបានបីរពាន់ប្រាំរយ បាយទឹកលើគេ។

ក៖ ច្រើនៗ?

ខ៖ នឹងយើងគិតថាច្រើនហើយពីរមុន។

ក៖
ហើយចុះបងបានរស់នៅតាំងពីរតូចរហូតមកដល់សព្វថ្ងៃនេះឪពុកម្ដាយរបស់បងគាត់បានធ្លាប់បង្រៀនបងអោយចេះជំនាញ់ដូចជាអើយធ្វើឧបករណ៏អីមួយសំរាប់ចឹញ្ចឹមជីវិតមកដល់សព្វថ្ងៃនេះធ្លាក់បង្រៀនអីខ្លះដល់បងទេ?

ខ៖ អត់សុតបើគាត់នឹងចេះតែធ្វើស្រែតែមួយមុខគាត់អត់មានជំនាញ់។

ក៖ បងអើយបងបានរស់នៅក្នុងជីវិតរបស់បងចេះជំនាញ់បង
ហើយមកបងចូលចិត្តម្ហូបអាហារបែកអីដែរបែកខ្មែរឬមួយក៏មិចដែរបែក?

ខ៖ បែកខ្មែរយើងនឹង! ខ្មែរបែកខ្មែរ! ។

ក៖ មានកូនចៅណាលែងឧបករណ៏ដន្រ្តីអីខ្លះទេ?

ខ៖ អត់! ផង។

ក៖  អើយចា៎ ចុះបងបានរស់នៅក្នុងជីវិតរបស់បងតាំងពីររហូតមកដល់ទល់សព្វថ្ងៃនេះ?

ខ៖ បាទ!។

ក៖ អើយបានរស់នៅពីរមុខមកផ្ទះពឹងណាដែរជាមួយឪពុកម្ដាយពីរវ័យកុមារមកដល់?

ខ៖ ពីរមុនផ្ទះតូចទេតែមកដល់ឥឡូវនឹងផ្ទះខ្ញុំធំ។

ក៖ ពេលដែរបងបានធំដឹងក្ដីផ្ទះមានរូបរាងមិចដែរ?

ខ៖ ផ្ទះតូចកាលនឹងណ៎! ផ្ទះតូច ពីរតូចល្លះធំឡើងចាប់ផ្ដើមធ្វើវារៀងធំតិច
ដល់ឥឡូវរុះធំតិចមកធ្វើធំជាងនឹងទៀតចឹងណា។

ក៖ បងខ្ញុំសុំសួរបងតិចកាលផ្ទះ តូចនឹងបងអាចស្រម៉ៃមើលតូច! តូចបែនលក្ខណផ្ទះ?

ខ៖ ផ្ទះនឹងប្រក់ស្លឹក។

ក៖ ផ្ទះស្លឹក?

ខ៖ ផ្ទះស្លឹកត្នោតអូន ស្លឹកត្នោតក្រាករនៀវអាស្សីយើងនឹងមិនទាន់
ស្លឹកទល់ហើយនឹងបានធ្វើផ្ទះឈើ ប្រក់ស្លឹកហើយ ផ្ទះឈើរនៀវអាស្សី លើប្រក់ក្បឿង។

ក៖ ចុះ អាស្សីដែរបាននិយាយនឹងអើយ! អើយសព្វថ្ងៃនឹង ផ្ទះមិចដែរ! ផ្ទះ ថ្មម៉ង?

ខ៖ សព្វថ្ងៃនេះផ្ទះឈើ មុនថ្ម លើឈើ តែប្រក់ក្បឿងនឹងង៍ដែរ។

ក៖ ជាកំលាំងញើរឈាម នរណាគេដែរ ជារបស់ម៉ាកប៉ា ផ្ទាល់?

ខ៖ របស់កំលាំងញើរឈាម ម៉ែឪ ផ្ទាល់ គាត់រកស៊ីខ្លួនគាត់ទេ របស់យើងផ្សេង
នឹងយើងធ្វើផ្សេង ។

ក៖ ដោយសារតឡូវនឹងយើងមានគ្រួសារទៅយើង បែកពីរគេ បែកផ្ទះផ្សេងពីរគ្នាៗ?

ខ៖ បាទ!។

ក៖ ចាំ!
បងនៅពេលដែរបងបានរស់នៅតាំងពីរតូចរហូតមកដល់សព្វថ្ងៃនេះបងធ្លាប់ឃើញឪពុកម្តាយបងបាននិយាយពីររឿងខ្មែរក្រហមអីខ្លះទេ ពីរជំនាន់អាប៉ុល?

ខ៖ គាត់ធ្លាប់និយាយ តើថាពីរមុនជំនាន់នយោបាយគេកាលនឹងគរអោយស្ទូនស្រូវអីនឹងទៅ
ហូបអីមិនបានសូវគ្រប់គ្រាន់! គ្រាន់តែកាលនេងសំបូររបស់ហូបតែគ្រាន់ថា
គេអត់សូវអោយហូបចឹងណា និយាយចឹងគេថាកន្លែងណាគេបានអោយហូប
គឺកន្លែងនឹងបានបបូរ គេចឹង មានកន្លែងណាអត់ៗ មានដោយកន្លែង
គាត់រ៉ែកកាលជំនាន់នឹងគាត់រ៉ែកដីរ៉ែកអីចឹង។

ក៖ ចាំ!  គាត់ធ្លាប់និយាយពីរជីវិតគាត់នឹងដែរបង?

ខ៖ នឹងហើយធ្លាប់ ថារ៉ែកដីអីចឹងទៅ។

ក៖ គាត់ធ្លាប់និយាយពីរជំនាន់អាប៉ុល
មានវត្តអារាមអីនឹងអីទៅសំរាប់អោយយើងនឹងបានថ្វាយបង្គំរាល់ថ្ងៃសីលអីមានដែរគាត់និយាយទេ?

ខ៖ នឹងដូចអត់ លឺផង អត់ដែរលឺគាត់និយាយ តែគ្រាន់ជំនាន់នឹងខ្ញុំបានឃើញវត្តមកពីរ
នឹងហើយតែខ្ញុំមិនបានសួរគាត់អារឿងចំណុត។

ក៖
បងសំរាប់បងផ្ទាល់បងបានរស់នៅតាំងពីរតូចរហូតមកដល់សព្វនេះលំបាកជាងគេនៅពេលណាដែរបង?

ខ៖ នៅពេល !
នៅពេលលំបាកជាងគេពេលដែរយើងនឹងអាយុខ្ទុងម៉ាម្ភៃជាងកាលនឹងលំបាក។

ក៖ អ្វីខ្លះដែរបងឆ្លងកាត់នៅក្នុងអាយុម៉ាម្ភៃជាងរបស់បង?

ខ កាលនឹងមានការខ្វះខាត់ច្រើនជីវភាព
ក្នុងគ្រួសារលុយអត់សូវមានចាយគិតចឹងហើយកាលនឹងយើងអត់ទាន់បានចេញ

យើងនឹងអត់ធ្វើកាងារអីចឹងទៅយើងរស់នៅក្នុងបន្ទុកគ្រួសារ! បន្ទុកគ្រួសារធម្មតាកូនសម័យមុនវាច្រើនគ្នាចឹងទៅយើងនឹងពិបាកដែរ ត្រូវការចំណាយវាយវាច្រើនកូនប្រាំបីរនាក់ចាយវាយក័អស់ច្រើនដែរចឹងជីវភាពគ្រួសារយើងនឹងក័យ៉ាប់យ៉ឺនដែរ មកដល់ឥឡូវនឹងយើងនឹងក័រៀងធូរធារជាងមុនដែរ។

ក៖ ចំា! ចុះពេលណាបានសប្បាយចិត្តជាងគេ?

ខ៖ ពេលដែរបានសប្បាយចិត្តជាងគេជំនាន់កាលនដែរយើងនៅរៀងក្មេងៗ មានចិត្តដ៏សប្បាយដល់ឥឡូវអត់ ដូចអត់សូវថាមានចិត្តថាសប្បាយអីអត់។

ក៖ ដោយសារយើងកើត មកយើងមានតែបញ្ហាចឹងបងនែ៎?

ខ៖ នឹងហើយ! នឹងហើយ!។

ក៖ ចំា! ដោយសារតែអើយជៅវភាពពួកយើងធំធាត់មកគឺនៅក្នុងត្រគូលរៀងអត់សូវជា?

ខ៖ នឹងហើយ អត់សូវមាន។

ក៖ អត់សូវធូរធារនឹងគេ?

ខ៖ បានតែម៉ាកេរៗ នឹងហើយបើគេមាន។

ក៖ ចឹងហើយធ្វើអោយជីវិតមានការតាមតឹងខ្លាំង បងអើយសំរាប់បងផ្ទាល់ខ្ញុំបានដឹងថាជីវិតរបស់បងមានការលំបាកច្រើនហើយក៏មិនមែនថាមានតែបងម្នាក់នៅលើលោកដែរពុបាកជាងគេ ?

ខ៖ នឹងហើយ! នឹងហើយ!។

ក៖ គឺមានច្រើន សូម្បីរតែខ្ញុំសូម្បីមនុស្សដ៍ទៃទៀតក័គេលំបាកចឹងដែរ?

ខ៖ បាទ!

ក៖ ចុះបងធំដឹងក្តីមកបងកាន់សាសន៍នឹងមក សាសន៍ព្រះពុទ្ធ?

ខ៖ បងកាន់សាសន៍ព្រះពុទ្ធ។

ក៖ ធ្លាប់មានគំណិតចឹងធ្លាក់ប្តូរសាសន៍អ្វីខ្លះទេ?

ខ៖ អ៊ឺរ! អារឿងនឹងអត់មានផង។

ក៖ ធ្លាប់តែមានអារម្មណ៏យើងកាន់សាសន៏ាព្រះពុទ្ធ យើងនឹងមានរៀងថាស្ងឹតស្ងារជាង?

ខ៖ នឹងហើយ! នឹងហើយ!។

ក៖ ចឹងណា ដោយសារ អើយនេះគឺជាសាសន៍មួយដែរអើយប្រទេសកម្ពុជាយើង! ប្រទេសកម្ពុជាយើងនឹងដាប់ផ្តើមមានពេលណាយយើងនឹងបានចាប់ផ្តើមមានព្រះពុទ្ធ?

ខ៖ នឹងហើយ! នឹងហើយ។

ក៖ ចឹងវាគ្រាន់តែជាអើយ សាសន៍អើយនៃប្រទេសកម្ពុជាយើងមួយកន្លែងដែរ សំរាប់បងតើបងអើយអាចប្រាប់ពីរអារម្មណ៏បងមកកាន់ក្មេងៗ

ជំនាន់ក្រោយខ្លះបានទេថាតើបងចង់និយាយអីខ្លះទៅកាន់គាត់ដើម្បីអោយគាត់អោយចេះតស៊ូរដើម្បីអោយគាត់ចេញជៀលវៀងនៅក្នុងកុំអោយមានផលពិបាករបស់គាត់?

ខ៖ អឺរ !

ក៖ ពិបាកអីចឹងណា?

ខ៖ ក្មេងៗ ជំនាន់ក្រោយអោយយើងនឹងតស៊ូរខំរៀនសូត្រខំអីចឹងណា ពីព្រោះយើងមានឧកាសបានរៀនសូត្រពីព្រោះអីសម័យនេះគេទៀមទៀងរកអ្នកមានជំនេះចឹង ទៀមទៀងដើម្បីរកអ្នកចេះដឹងពីព្រោះប្រទេសយើងឥឡូវជឿនលឿម បើថាយើងនឹងអត់ចេះដឹង យើងអត់ធ្វើយើងបានតែត្រឹមកាងារនៅខាងក្រៅ បើគេចេះដឹងអីទៅគេអាចធ្វើការក្នុងម៉ាស៊ីនត្រជាក់ឬមួយក៏ធ្វើការនៅកន្លែងណាមួយរបស់ដែរស្រួយជាងយើងដែរយើងអត់សូវចេះអត់សូវអីចឹងណាអូន។

ក៖ ចាំ! នៅពេលដែរបងធ្លាប់មានអារម្មណ៍ថាអញ្ចេកក្មេងៗ សម័យឥឡូវនឹងណាគឺមានការភ្លឹកភ្លឹងច្រើនប្រទេសកាន់តែអភិវឌ្ឍន៍ប៉ុន្តែក្មេងក៏កាន់តែមានការភ្លែកបែនផ្សេងគ្នាច្រើនចឹងណា បងធ្លាប់គេនិយាយពីរគ្រឿងញៀនខ្លះទេបង?

ខ៖ ធ្លាប់! អូន។

ក៖ ចាំ! ចុះសំរាប់បងផ្ទាល់បងគួរតែស្អប់ខ្ពើម ឬមួយក៏គ្រាំទ្រ?

ខ៖ បងស្អប់ខ្ពើម ចំពោះគ្រឿងញៀន ពីរព្រោះគ្រឿងញៀន វាបាននាំអោយបំផ្លាញអានាគត់ក្មេងៗ ក្មេងជំនាន់ក្រោយនេះ បំផ្លាញអានាគត់អើយប្រទេសជាតិយើងទាំងមូល។

ក៖ ចាំ ចុះបើសម័យយើងឥឡូវនេះ ហើយបងឯងធ្លាប់គិតស្រម៉ៃនេះក្មេងចាប់ផ្តើមភ្លឹកភ្លឹងមួយអើយសម័យស្អប់ខ្ពើមក៏មកពីរគ្រឿងញៀន ហើយក្នុងការឆក់លួច គឺបង្កើតអោយគឺដោយសារតែគ្រឿងញៀន ចាំ ! បើអត់មានគ្រឿងញៀននឹងពួកយើងគឺមិនអាចមនុស្សច្រើនដែរគេបានធ្វើការខុសច្បាស់ចឹងណាគឺដោយសារតែមនុស្សម្នាក់គេជ្រើរើសផ្លូវគឺដោយសារទល់ដែរ?

ខ៖ ត្រូវ។

ក៖ ចាំ ចឹងអើយចំពោះបងយើងសូមអោយក្មេងជំនាន់ក្រោយជៀសវៀងដូចជាការប្រើប្រាកគ្រឿងញៀន ដូចជាអំពើឧបាយមុខ ដូចជាលែងល្បែងផឹកស៊ីឬមួយក៏បានដើរវ៉ៃគ្នាកាប់ចាក់គ្នាអីនឹង ហើយឆក់ផ្លប់អីចឹងណាយើងសូមអោយក្មេងជំនាន់ក្រោយហើយនៅពេលដែរគាត់បានស្តាប់សំម្លេងអ្នកជំនាន់មុនណាសូមអោយជៀសវៀង ដោយសារតែខ្សែរជីវិតរបស់ម្នាក់ៗ ទំរាំតែធំដឹងក្តី ទំរាំតែបានកសាងគ្រួសារមកផ្ទាល់ដោយខ្លួនឯងនេះស្ទឹតតែបានឆ្លងកាត់ឧបសគ្គច្រើន?

ខ៖ ត្រូវហើយអូន ! ត្រូវហើយ។

ក៖ ចាំ! មិនមែនចេះតែងាយៗគ្រាន់តែម៉ាកដាំបាយមួយពេលៗដើម្បីចិញ្ចឹមយើងមួយថ្ងៃៗ បីរពេលនឹងគិតថាស្រួយទេ ការពិតគាត់ទ្រាំតែបានអត្តអោយយើងនឹងបានញ៉ាំក៏គាត់នឹងវេនាដែរណា?

ខៈ បាទ! បាទអូន! បាទ!។

កៈ ចឹងសូមអោយក្មេងជំនាន់ក្រោយជៀសវៀងសូមអោយធ្វើអ្វីដែរល្អៗ ក្នុងជីវិត
នៅក្នុងសង្គមផងដែរ សំរាប់បងផ្ទាល់តើបងមានអ្វីចង់បន្ថែមទៀតទេបង
ចង់និយាយទៀតទេ?

ខៈ អត់ទេ អស់ហើយ! ។

កៈ ចាំ
ចឹងអើយសំរាប់ខ្ញុំសូមណែនាំខ្លួនខ្ញុំម្តងទៀតដោយសារតែខ្ញុំបានធ្វើការនៅក្នុងកម្រងជីវប្រវិ
ត្តប្រជាជនខ្មែរ គឺខ្ញុំពិតជាស្រឡាញ់កម្រងមួយនឹងខ្លាំងមែនទែន
ដោយសារតែកម្រងមួយនឹងបានជួយយើងច្រើនក្នុងជីវិតរបស់យើង នឹង
ហើយជាពិសេសខ្ញុំសុំអនុញ្ញាតយកសម្លេងរបស់បងយកទៅដាក់ក្នុងគេហ័រទំព័រហើយនៅកា
ត់បូសឹបទៅកាន់បងណាដែរមានឈ្មោះ នៀម cambodianoralhisefories.byu.edu
នៅនៀមបងចឹងតើបងអនុញ្ញាតព្រមអោយខ្ញុំយកសម្លេងរបស់បងទុកអោយក្មេងៗជំនាន់
ក្រោយចូលទៅស្តាប់អោយគេបានស្តាប់នឹងបានទេ?

ខៈ នឹងអត់អីទេ។

កៈ ចាំ អរគុណបង ហើយខ្ញុំសុំថតរូបបងមួយបានទេជានឹងខ្ញុំអីដែរ?

ខៈ អឺរ អត់បាន! អត់ព្រម !។

កៈ ចឹងនែ៎ បងអត់ព្រមអនុញ្ញាតអោយខ្ញុំថតរូបបង ?

ខៈ បាទ! បាទ! ។

កៈ ចឹងអត់អីទេបង! ចឹង
ដូចខ្ញុំបានបញ្ជាក់បងចឹងថានៅពេលដែរខ្ញុំបានធ្វើការសម្ភាសនឹងបងគឺខ្ញុំបានធ្វើឡើងនៅ
ថ្ងៃទី០២ ខែ០២ ឆ្នាំ ២០២០បងណា ចាំចឹងសំរាប់ចឹងសូមអរគុណសំរាប់ជំរាបលា
ជូនពរបងសុខភាពល្អ?

ខៈ បាទ ។